# នីតិអន្តរជាតិសាធារណៈ
# PUBLIC INTERNATIONAL LAW

## មេរៀនទី ៥

LECTURE 5

## ទំនៀមទម្លាប់អន្តរជាតិ

CUSTOMARY INTERNATIONAL LAW

# មាតិកា

- កម្មវត្ថុនៃមេរៀន
- ផ្នែកទី១ សេចក្តីផ្តើម
- ផ្នែកទី២ ធាតុផ្សំសម្ភារៈនៃទំនៀមទម្លាប់
  - កិច្ចបង្កើតទំនៀមទម្លាប់
  - លក្ខខណ្ឌពេលវេលា
- ផ្នែកទី៣ ធាតុផ្សំចិត្តវិទ្យានៃទំនៀមទម្លាប់
  - សញ្ញាណទូទៅ
  - អានុភាពនៃទំនៀមទម្លាប់
- ផ្នែកទី៤ ការចងក្រងទំនៀមទម្លាប់
  - សញ្ញាណទូទៅ
  - របៀបចងក្រង
  - វិសាលភាពនៃការចងក្រង

# កម្មវត្ថុនៃមេរៀន

មេរៀនស្ដីអំពី ទំនៀមទម្លាប់អន្តរជាតិ មានគោលបំណងឲ្យអ្នកសិក្សាបានស្វែងយល់ពីៈ

- អ្វីទៅជាទំនៀមទម្លាប់
- តើទំនៀមទម្លាប់មានធាតុផ្សំអ្វីខ្លះ?
- ទំនៀមទម្លាប់ត្រូវគោរពនូវលក្ខខណ្ឌសុពលភាពអ្វីខ្លះ?
- តើកិច្ចអ្វីខ្លះដែលចូលរួមក្នុងការបង្កើតជាទំនៀមទម្លាប់?
- ស្វែងយល់ពីគុណសម្បត្តិនៃការចង់ក្រងបទដ្ឋានទំនៀមទម្លាប់ឲ្យទៅជាសន្ធិសញ្ញា

# ផ្នែកទី១ សេចក្តីផ្តើម

ទំនៀមទម្លាប់ គឺប្រភពចម្បង់នៃនីតិអន្តរជាតិសាធារណៈ ហើយទំនៀមទម្លាប់ក៏ត្រូវបានទទួលដោយមាត្រា២៨ នៃលក្ខន្តិកៈរបស់តុលាការយុត្តិធម៌អន្តរជាតិផងដែរ។ តើអ្វីទៅគឺជាទំនៀមទម្លាប់? ទំនៀមទម្លាប់ គឺជាការអនុវត្តតៗ ដែលមានលក្ខណៈជាទូទៅ ហើយវាត្រូវបានគេចាត់ទុកដូចជាច្បាប់។

# ផ្នែកទី១ សេចក្ដីផ្ដើម

បណ្ដាលរដ្ឋជាសមាជិករបស់អង្គការសហប្រជាជាតិ បានចាត់ទុំនៀមទម្លាប់អន្តរជាតិ គឺជាប្រភពមួយដ៏សំខាន់ខានមិននៃនីតិអន្តរជាតិ។ ម្យ៉ាងវិញទៀតបីនៅក្នុងធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ ក៏ដូចជានៅក្នុងលក្ខខ្ដិកៈរបស់តុលាការយុត្តិធម៌អន្តរជាតិបានទទួលការអនុវត្តដោយបង្ខំនូវបទដ្ឋានទំនៀមទម្លាប់អន្តរជាតិ នៅពេលដោះស្រាយវិវាទចំពោះមុខតុលាការ។

# ផ្នែកទី១ សេចក្ដីផ្ដើម

ទំនៀមទម្លាប់មួយអាចត្រូវបានគេទទួលស្គាល់បាន លុះណាវាគោរពនូវលក្ខខណ្ឌមួយចំនួនផងដែរ ជាពិសេសវាត្រូវមានធាតុផ្សំដ៏សំខាន់ចំនួនពីរគឺ ធាតុផ្សំជាសម្ភារៈ និងធាតុផ្សំចិត្តវិទ្យា (ដែលគេសំដៅដល់លក្ខណៈចាប់បង្ខំ)។ យើងនឹងសិក្សាពីធាតុផ្សំទាំងពីរនេះនៅក្នុងផ្នែកទី២ និងទី៣នៃមេរៀននេះ។

# ផ្នែកទី១ សេចក្ដីផ្ដើម

សូមធ្វើការបញ្ជាក់ផងដែរថា ទំនៀមទម្លាប់អាចត្រូវបានបែងចែកជាបីគឺ ទំនៀមទម្លាប់អន្តរជាតិ (សាកល) ទំនៀមទម្លាប់ថ្នាក់តំបន់ និងចុងក្រោយគឺទំនៀមទម្លាប់ក្នុងស្រុក (ពេលខ្លះគេហៅថាទំនៀមទម្លាប់ថ្នាក់មូលដ្ឋាន)។ ទំនៀមទម្លាប់ថ្នាក់តំបន់អាមានលក្ខណៈតឹងរឹងជាគេ។

# ផ្នែកទី២ ធាតុផ្សំសម្ភារៈនៃទំនៀមទម្លាប់

ប្រសិនបើនិយាយពីធាតុផ្សំសម្ភារៈ នោះគេសំដៅទៅដល់ការអនុវត្តដែលបង្កើត ដែលការអនុវត្តទាំងនោះ អាចជាការអនុវត្តរបស់រដ្ឋ ឬ អង្គការអន្តរជាតិ ឬ នីតិបុគ្គលឯកជនផ្សេងទៀត រួមមានដូចជា អង្គការក្រៅរដ្ឋាភិបាល ឬ ក្រុមហ៊ុនពហុជាតិជាដើម។

# ផ្នែកទី២ ធាតុផ្សំសម្ភារៈនៃទំនៀមទម្លាប់

ការអនុវត្តដែលអាចបង្កើតទៅជាទំនៀមទម្លាប់បាន អាជាកើតចេញពីកិច្ចវិជ្ជមាន (ទង្វើសកម្ម ឬ អំពើជាក់ស្តែង) និងក៏អាចកើតចេញពីកិច្ចអវិជ្ជមាន (ទង្វើអកម្ម ឬ ការដែលនៅស្ងៀមមិនធ្វើការសំដែងអំពើ ឬ សកម្មភាពណាមួយ)។ កិច្ចដែលជាការអនុវត្ត ដាច់ខាតត្រូវតែសំដែងឡើងដោយតួអង្គរបស់នីតិអន្តរជាតិ ត្រូវធ្វើឡើងជាទៀងទាត់ និងមានលក្ខណៈជាទូទៅផងដែរ។

# ផ្នែកទី២ ធាតុផ្សំសម្ភារៈនៃទំនៀមទម្លាប់

- កិច្ចបង្កើតទំនៀមទម្លាប់

ក. កិច្ចរបស់រដ្ឋៈ គឺជាកិច្ចដែលស្តែងឡើងដោយស្ថាប័នណាមួយរបស់រដ្ឋ ដែលកិច្ចនោះបានបង្ករឲ្យមានទំនាក់ទំនងទៅខាងក្រៅ (ទំនាក់ទំនងអន្តរជាតិ)។ ជាទូទៅ គឺគេសំដៅទៅអាជ្ញាធរ ឬ ស្ថាប័នទទួលបន្ទុកទំនាក់ទំនងអន្តរជាតិ (សម្រាប់ប្រទេសកម្ពុជា គឺក្រសួងការបរទេស និងសហប្រតិបត្តការអន្តរជាតិ)។

# ផ្នែកទី២ ធាតុផ្សំសម្ភារៈនៃទំនៀមទម្លាប់

- កិច្ចបង្កើតទំនៀមទម្លាប់

ក. កិច្ចរបស់រដ្ឋ: អាចជាកិច្ច ឬ សកម្មភាពដែលទាក់ទងទៅនិងច្បាប់ជាតិក្នុងវិស័យច្បាប់អន្តរជាតិ ក៏អាចសកម្មភាពក្នុងបង្កើតជាទំនៀមទម្លាប់អន្តរជាតិបានផងដែរ ដូចជាទាក់ទងទៅនិងការធ្វើជាតូបនីយកម្ម ឬ អភ័យឯកសិទ្ធិរដ្ឋ ឬ អាចជាកិច្ចរបស់តុលាការផ្ទៃក្នុង ជាអាទិ៍។

# ផ្នែកទី២ ធាតុផ្សំសម្ភារៈនៃទំនៀមទម្លាប់

- កិច្ចបង្កើតទំនៀមទម្លាប់

ខ. កិច្ចអន្តរវដ្ដៈ កិច្ចនេះគឺចាប់ផ្ដើមចេញពីសន្ធិសញ្ញាមួយចំនួនដែលពីដំបូងមានការទទួលស្គាល់ដោយរដ្ឋភាគតិច តែក្រោយមកទៀតមានការទទួលស្គាល់ជាទូទៅ។ ម្យ៉ាងវិញទៀនសន្ធិសញ្ញាមួយចំនួនទៀតបានធ្វើការទទួលស្គាល់ជាចំហរនូវទំនៀមទម្លាប់ដែលមានកន្លងមក ដូចជាអនុសញ្ញាឡាអេស្តីពីច្បាប់ និងទំនៀមទម្លាប់លើផែនដី ជាអាទ៏។

# ផ្នែកទី២ ធាតុផ្សំសម្ភារៈនៃទំនៀមទម្លាប់

- កិច្ចបង្កើតទំនៀមទម្លាប់

ខ. កិច្ចអន្តររដ្ឋ: កិច្ចមួយចំនួនទៀតកើតចេញពីសកម្មភាពរបស់តុលាការអន្តរជាតិ ឬ មជ្ឈត្តការអន្តរជាតិ ក៏អាចចូលរួមក្នុងការបង្កើតទំនៀមទម្លាប់អន្តរជាតិដែរ ដោយសារតែសាលក្រម ឬ មជ្ឈត្តវិនិច្ឆ័យមួយចំនួន គឺជាកិច្ចលើកដំបូង ហើយវាត្រូវបានគេយកមកធ្វើជាគំរូសម្រាប់រឿងក្តីនាពេលក្រោយៗមកទៀត។

# ផ្នែកទី២ ធាតុផ្សំសម្ភារៈនៃទំនៀមទម្លាប់

- កិច្ចបង្កើតទំនៀមទម្លាប់

គ. កិច្ចរបស់អង្គការក្រៅរដ្ឋាភិបាលៈ ទំនៀមទម្លាប់វាក៏អាចកើតចេញពីក្របខណ្ឌនៃការអនុវត្តនៅក្នុងវិស័យឯកជន ដូចជាកិច្ចសន្យាអន្តរជាតិ ទាក់ទងទៅនឹងសកម្មភាពនៃការធ្វើពាណិជ្ជកម្ម ឬ ការធ្វើការវិនិយោគក្រៅប្រទេស ឬ កិច្ចមួយចំនួនទៀតទាក់ទងទៅនិងវិស័យមនុស្សធម៌ នៃអង្គការអន្តរជាតិមួយចំនួនផងដែរ។

# ផ្នែកទី២ ធាតុផ្សំសម្ភារៈនៃទំនៀមទម្លាប់

- លក្ខខណ្ឌពេលវេលា

ប្រសិនបើគេនិយាយពេលក្ខខណ្ឌពេលវេលា ទំនៀមទម្លាប់មួយអាចមានអាទិភាពទៅបាន លុះណាតែវាត្រូវបានគេអនុវត្តយ៉ាងជាប់លាប់ ព្រមជាមួយត្រូវមានលក្ខណៈជាឯកសណ្ឋានថែមទៀតផង។ ការអនុវត្តន៍វបទដ្ឋានទំនៀមទម្លាប់នោះ ត្រូវតែមានលក្ខណៈជាបន្តបន្ទាប់ជាប់ឥតដាច់ជារាងរហូតមក។

# ផ្នែកទី២ ធាតុផ្សំសម្ភារៈនៃទំនៀមទម្លាប់

- លក្ខខណ្ឌពេលវេលា

ទោះជាយ៉ាងណាក៏ដោយ ដើម្បីអាចក្លាយទៅជាទំនៀមទម្លាប់អន្តរជាតិបានវាត្រូវគោរពនូវលក្ខខណ្ឌបីចំនុចដូចជា៖

ក. ត្រូវមានការចូលរួមពីសំណាក់រដ្ឋដែលពាក់ព័ន្ធ

ខ. ការចូលរួមត្រូវមានលក្ខណៈគតិយុត្ត

គ. រដ្ឋតតិយភាគីអាចជំទាស់ក្នុងការអនុវត្តទំនៀមទម្លាប់ថ្មី

# ផ្នែកទី៣ ធាតុផ្សំចិត្តវិទ្យានៃទំនៀមទម្លាប់

- សញ្ញាណទូទៅ

ដើម្បីទទួលបាននូវការទទួលនូវវិធានទំនៀមទម្លាប់មួយ ថាដូចជាច្បាប់ ត្រឹមតែបង្ហាញនូវការអនុវត្តគឺមិនទាន់គ្រប់គ្រាន់ឡើយ វាត្រូវតែមានការទទួលស្គាល់ពីលក្ខណៈចាប់បង្ខំនៃទំនៀមទម្លាប់នោះថែមទៀត ពីសំណាក់រដ្ឋទាំងឡាយ និងជាពិសេសពីសំណាក់រដ្ឋដែលពាក់ព័ន្ធ។

# ផ្នែកទី៣ ធាតុផ្សំចិត្តវិទ្យានៃទំនៀមទម្លាប់

- សញ្ញាណទូទៅ

មានសំនួរមួយត្រូវបានគេចោទសួរថា តើរវាងធាតុផ្សំទាំងពីរ គឺធាតុផ្សំសម្ភារ:(អ័នុវត្ត) និងធាតុផ្សំចិត្តវិទ្យា(បង្ខំ) ធាតុផ្សំមួយណាកើតមុន? មានការលើកឡើងខុសៗក្នុងចំណោមអ្នកសិក្សា អ្នកសិក្សាមួយចំនួនអះអាងថា ការអនុវត្តត្រូវកើតមុន ប៉ុន្តែមានអ្នកសិក្សាមួយចំនួនទៀតបានអះអាងថាការ័បង្ខំកើតមុន។

# ផ្នែកទី៣ ធាតុផ្សំចិត្តវិទ្យានៃទំនៀមទម្លាប់

- អានុភាពនៃទំនៀមទម្លាប់

បើវាត្រូវបានគេទទួលស្គាល់ជាទូទៅ ជាឯកសណ្ឋាន និង យ៉ាងទូលំទូលាយ ពេលនោះហើយដែលបទដ្ឋាននោះត្រូវបានគេចាត់ទុកថាជាទំនៀមទម្លាប់។ សូមបញ្ជាក់ផងដែរថា បទដ្ឋានដែលជាទំនៀមទម្លាប់ គឺមានលក្ខណៈតឹងរឹងជាងបទដ្ឋានដែលសន្និសញ្ញា។

# ផ្នែកទី៣ ធាតុផ្សំចិត្តវិទ្យានៃទំនៀមទម្លាប់

- អានុភាពនៃទំនៀមទម្លាប់

ព្រោះថា សន្និសញ្ញាមានអានុភាពចំពោះរដ្ឋដែលទទួលយកវាតែប៉ុណ្ណោះ ចំណែកឯទំនៀមទម្លាប់វិញគឺវាមិនរើសមុខឡើយ។ ម្យ៉ាងវិញទៀត សម្រាប់សន្និសញ្ញាគេអាចស្នើធ្វើខដាក់លក្ខខណ្ឌបាន ផ្ទុយទៅវិញទំនៀមទម្លាប់គេមិនស្នើធ្វើខដាក់លក្ខខណ្ឌបានឡើយ។

# ផ្នែកទី៤ ការចង់ក្រងទំនៀមទម្លាប់

មានសំនួរតែងត្រូវបានលើកឡើងជាញឹកញាប់ អំពីមូលហេតុនៃការចង់ក្រងបទដ្ឋានទំនៀមទម្លាប់ ឲ្យទៅជាបទដ្ឋានដែលមានលក្ខណៈជាលាយលក្សណ៍អក្សរ? ប្រសិនបើបទដ្ឋានទំនៀមទម្លាប់ អាចអនុវត្តបានដូចទៅនឹងសន្ធិសញ្ញាដែរ តើហេតុអ្វីបានជាគេត្រូវចំណាពេលវេលា និងថវិការក្នុងទំនៀមទម្លាប់? ចម្លើយទៅនិងសំនួរទាំងនេះនឹងឆ្លើយនៅខាងក្រោមជាបន្តបន្ទាប់នៃមេរៀននេះ។

# ផ្នែកទី៤ ការចង់ក្រងទំនៀមទម្លាប់

- សញ្ញាណទូទៅ

ការចង់ក្រងបទដ្ឋានដែលមានលក្ខណៈជាទំនៀមទម្លាប់ ឲ្យទៅជាបទដ្ឋានដែលមានលក្ខណៈលាយលក្សណ៍អក្សរ ដែលហៅថាសន្ធិសញ្ញា គឺក្នុងគោលបំណងថែរក្សានូវសណ្ដាប់ធ្នាប់ និងរបៀបរាបរយនៃបទដ្ឋានទំនៀមទម្លាប់ ម្យ៉ាងវិញទៀត ការចង់ក្រងនេះក៏ក្នុងចេតនាដើម្បីរក្សានូវសុវត្ថិភាពដល់ទំនៀមទម្លាប់នោះ។

# ផ្នែកទី៤ ការចង់ក្រងទំនៀមទម្លាប់

- សញ្ញាណទូទៅ

ដោយយោងតាមបញ្ញត្តិនៃមាត្រា១៣ នៃធម្មនុញ្ញរបស់អង្គការសហប្រជាតិ គឺត្រូវបានប្រគល់ភារកិច្ចផ្តាច់មុខនៃការចងក្រងបទដ្ឋានទំនៀមទម្លាប់នេះ ទៅឲ្យមហាសន្និបាទរបស់អង្គការសហប្រជាតិ។

# ផ្នែកទី៤ ការចង់ក្រងទំនៀមទម្លាប់

- សញ្ញាណទូទៅ

គណៈកម្មការច្បាប់អន្តរជាតិមួយត្រូវបានបង្កើតឡើង នៅឆ្នាំ ១៩៧៤ ក្នុងគោលបំណងសម្របស័ម្រួលការងារនៃការចង់ក្រងនេះ ហើយដែលគណៈកម្មការនេះមានសមាសភាពចំនួន ៣៤ រូប ដែលត្រូវបានជ្រើសតាំងឡើងដោយមហាសន្និបាតរបស់អង្គការសហប្រ៉ជាជាតិ។ អ្នកច្បាប់ទាំង៣៤រូបនេះ មិនបំពេញការងារក្នុងនាមរដ្ឋរបស់ខ្លួនដែលមានសញ្ជាតិនោះឡើយ។

# ផ្នែកទី៤ ការចង់ក្រងទំនៀមទម្លាប់

- សញ្ញាណទូទៅ

មុខងារសំខាន់របស់គណៈកម្មការនេះ គឺអនុម័តនូវរាល់អនុសញ្ញាអន្តរជាតិទាំងឡាយ ហើយដែលក្នុងនោះ មានអនុសញ្ញាទីក្រុងវីយែន ឆ្នាំ១៩៦៩ ស្តីពីច្បាប់សន្ធិសញ្ញារវាងរដ្ឋនិងរដ្ឋ គឺជាភាស្តុតាងដែលមិនអាចប្រកែកបាន។

# ផ្នែកទី៤ ការចង់ក្រងទំនៀមទម្លាប់

• សញ្ញាណទូទៅ

ទន្ទឹមនឹងគ្នានេះផងដែរ គណៈកម្មការច្បាប់អន្តរជាតិមួយទៀតក៏ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៦៦។ គណៈកម្មការនេះមានឈ្មោះថា៎ គណៈកម្មការអង្គការសហប្រជាជាតិសម្រាប់នីតិពាណិជ្ជកម្មអន្តរជាតិ ដែលមានសមាសភាពចំនួន៣៦ ដែលជ្រើសរើសចេញពីរដ្ឋដែលជាភាគី។ អ្នកច្បាប់ទាំង៣៦រូប បំពេញតួទានីរបស់ខ្លួនដោយឯករាជ្យពីរដ្ឋដែលខ្លួនមានសញ្ជាតិ។

# ផ្នែកទី៤ ការចង់ក្រងទំនៀមទម្លាប់

- របៀបចង់ក្រង

នៅពេលដែលត្រូវធ្វើការចង់ក្រង គណៈកម្មការច្បាប់អន្តរជាតិរបស់អង្គការសហប្រជាជាតិនេះ ត្រូវធ្វើការចាត់តាំងអ្នករាយការណ៍ពិសេស ដើម្បីសិក្សាស្រាវជ្រាវរកនូវប្រធានបទណាមួយដែលគេគិតថាវាសំខាន់សម្រាប់សង្គមអន្តរជាតិបច្ចុប្បន្ន។

# ផ្នែកទី៤ ការចង់ក្រងទំនៀមទម្លាប់

- របៀបចងក្រង

បន្ទាប់មកសមាជិកគណៈកម្មការ នឹងធ្វើការជជែកពិភាក្សាគ្នាទៅលើរបាយការណ៍ ដែលអ្នករាយការណ៍ពិសេសបានដាក់ជូន។ ពួកគេនឹងធ្វើការផ្ញើរនូវកម្រងសំនួរទៅឲ្យរដ្ឋាភិបាលដែលជាសមាជិករបស់អង្គការសហប្រជាជាតិ និងទទួលត្រឡប់មកវិញនូវការឆ្លើយតបរបស់រដ្ឋាភិបាលទាំងនោះ។

# ផ្នែកទី៤ ការចង់ក្រងទំនៀមទម្លាប់

- វិសាលភាពនៃការចង់ក្រង

ទោះបីត្រូវបានចង់ក្រងទៅហើយក៏ដោយ ក៏ទំនៀមទម្លាប់នៅតែបន្តនូវការអនុវត្ត រហូតដល់មានការចូលជាធរមាននូវវិធានដែលទើបត្រូវបានចង់ក្រងនោះ។ ក្រោយពីការចូលជាធរមាន បទដ្ឋានដែលត្រូវបានចង់ក្រង គឺមានវិសាលភាពយកទៅអនុវត្តចំពោះតែរដ្ឋដែលទទួលយកវាតែប៉ុណ្ណោះ។

# ផ្នែកទី៤ ការចង់ក្រងទំនៀមទម្លាប់

- វិសាលភាពនៃការចង់ក្រង

ទោះបីត្រូវបានចង់ក្រង ទៅជាបទដ្ឋានជាលាយលក្សណ៍អក្សរហើយក៏ដោយ ក៏ទំនៀមទម្លាប់នោះមិនត្រូវបានទាត់ចោលឡើយ។ ពីព្រោះថា នៅក្នុងនីតិអន្តរជាតិពុំមានបាតុភូតនៃការស្រូបយក ឬ ក៏បាតុភូតនៃការជំនួសរវាងទំនៀមទម្លាប់ និងបទដ្ឋានជាលាយលក្សណ៍អក្សរនោះទេ។

# ផ្នែកទី៤ ការចច់ក្រខទំនៀមទម្លាប់

- វិសាលភាពនៃការចង់ក្រង

ការចង់ក្រងមិនលុបបំបាត់នូវតម្លៃរបស់ទំនៀមទម្លាប់ទេ គឺការចង់ក្រង់គ្រាន់តែជួយបន្ថែមនូវវិសាលភាពគតិយុត្តទៅឲ្យទំនៀមទម្លាប់។ ក្នុងន័យនេះ ទំនៀមទម្លាប់នៅតែមានតម្លៃសម្រាប់រដ្ឋដែលមិនទទួលយកនូវបទដ្ឋានជាលាយលក្សណ៍អក្សរ ដែលទើបត្រូវបានបង្កើតឡើង។ ដូច្នេះ ទំនៀមទម្លាប់ និងសន្ធិសញ្ញា គឺមានទំនាក់ទំនងគ្នា និងបំពេញឲ្យគ្នាទៅវិញទៅមក។

មេរៀនទី៥ ស្ដីពីទំនៀមទម្លាប់អន្តរជាតិ ត្រូវបានបញ្ចប់សូមអរគុណ សម្រាប់ការតាមដានដោយយកចិត្តទុកដាក់ពីសំណាក់អ្នកសិក្សាទាំងឡាយ។